**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
លេខ....១០៥២.......អពដ.នកទ

L202401150462TD2866

ថ្ងៃចន្ទ ៤រោច ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

## ជម្រាបជូន
## លោក-លោកស្រីនាយក

ឈ្មោះសហគ្រាស ៖ ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
ជាអក្សរឡាតាំង ៖ GRANT THORNTON ( CAMBODIA ) LIMITED
លេខអត្តសញ្ញាណកម្ម ៖ L001-104007702 ចុះបញ្ជីនៅ៖ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អាសយដ្ឋាន ៖ ផ្ទះលេខ ៣១៥ វិមានកាណាឌីយ៉ា ផ្លូវ ព្រះមុនីវង្ស កែងផ្លូវ ព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

---

**កម្មវត្ថុ៖** លិខិតបញ្ជាក់ការកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ។
**យោង** ៖ - ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់
- ប្រកាសលេខ ៦៣៨ សហវ.ប្រក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីនៃការបង់ពន្ធអប្បបរមា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក-លោកស្រីនាយកសហគ្រាស ជ្រាបថា សហគ្រាសបានដាក់លិខិតមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំលទ្ធផលនៃការវាយតម្លៃការកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ ពីគណៈកម្មការវាយតម្លៃការកាន់កាប់បញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ។

អនុលោមតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ និងការពិនិត្យយ៉ាងហ្មត់ចត់លើឯកសារពាក់ព័ន្ធ ព្រមទាំងសាវតារនៃការអនុវត្តកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសលោក-លោកស្រី គណៈកម្មការវាយតម្លៃការកាន់កាប់បញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធ សម្រេចវិនិច្ឆ័យថាសហគ្រាសបានកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវ និងផ្តល់ជូនលិខិតបញ្ជាក់ការកាន់បញ្ជិកាគណនេយ្យត្រឹមត្រូវចាប់ពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៥ ដើម្បីទទួលបានអត្ថប្រយោជន៍នានា ស្របតាមប្រកាសលេខ ៦៣៨ សហវ.ប្រក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧។

ទន្ទឹមនឹងនេះ លោក-លោកស្រីនាយកសហគ្រាស ត្រូវបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវកាតព្វកិច្ចសារពើពន្ធនានា ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។ អគ្គនាយកដ្ឋានពន្ធដារ រក្សាសិទ្ធិក្នុងការដកហូត លិខិតបញ្ជាក់ និងមោឃភាពនូវអត្ថប្រយោជន៍នានាដែលបានផ្តល់ជូនក្នុងអំឡុងពេលនេះ ព្រមទាំងទទួលរងពិន័យ និងទោសទណ្ឌផ្សេងៗទៀត ក្នុងករណីមានការរកឃើញថា សហគ្រាសលោក-លោកស្រី ពុំបានអនុវត្តកាតព្វកិច្ចសារពើពន្ធឱ្យបានខ្ជាប់ខ្ជួនស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារនោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីនាយកសហគ្រាស អនុវត្តតាមការសម្រេចនេះ។
សូម លោក-លោកស្រីនាយកសហគ្រាស ទទួលនូវសេចក្តីរាប់អាន ពីខ្ញុំ

**ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ**

**ឡៀម រដ្ឋា**

**ចម្លងជូន៖**
-នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
-នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
-នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
-ឯកសារ-កាលប្បវត្តិ